# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា១ មាត្រា២ នៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីចំណូល និងការបែងចែកចំណាយ មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ "អប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រាមួយ .-**

មាត្រា១ និងមាត្រា២ នៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីចំណូល និងការបែងចែកចំណាយមូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា១ .-ថ្មី**

អនុញ្ញាតឱ្យប្រើប្រាស់ចំណូលចំនួន២០% (ម្ភៃភាគរយ) នៃចំណូលដុលប្រចាំឆ្នាំរបស់ "គ្រឹះស្ថានអង្គរ" ដែលទទួលបានពីការលក់ប័ណ្ណចូលទស្សនាតំបន់រមណីយដ្ឋានអង្គរជា **មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ**។

**មាត្រា២ .-ថ្មី**

ចំណាយ**មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ** ត្រូវបានគ្រោងជាចំណាយមិនទាន់បែងចែកមានមុខសញ្ញារបស់រាជរដ្ឋាភិបាល នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ សម្រាប់បែងចែកដល់គោលដៅនៃការប្រើប្រាស់ប្រចាំឆ្នាំ តាមអត្រាដូចខាងក្រោម៖

១.អាជ្ញាធរអប្សរា ចំនួន៨០% សម្រាប់ជាគុណប្រយោជន៍ក្នុងការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។ អាជ្ញាធរអប្សរាត្រូវប្រើប្រាស់មូលនិធិនេះមួយចំនួនសម្រាប់ការអភិវឌ្ឍតំបន់ប្រាសាទព្រះវិហារ។

២.សាលាខេត្តសៀមរាប ចំនួន៩% ដើម្បីធ្វើការអភិវឌ្ឍបន្ថែមសម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រដែលរស់នៅជុំវិញតំបន់អង្គរ និងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប។

៣.ក្រសួងទេសចរណ៍ ចំនួន៤% ក្នុងគោលដៅបង្កើតផលិតផលទេសចរណ៍ថ្មីៗបន្ថែមទៀត ដើម្បីរុញសក្តានុពលទេសចរណ៍កម្ពុជា និងកំណើនសេដ្ឋកិច្ច។

៤.ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំនួន៤% ដើម្បីធ្វើការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិទាំងរូបិយ និងអរូបិយ។

៥.អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ ចំនួន៣% ដើម្បីបែងចែកជូនដល់អង្គភាពនគរបាលទេសចរណ៍ ដោយផ្អែកលើផែនការច្បាស់លាស់ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍ ដើម្បីជួយដល់អង្គភាពនគរបាលទេសចរណ៍តាមគោលដៅសំខាន់ៗ ក្នុងការលើកកម្ពស់



សមត្ថភាព ប្រសិទ្ធភាពនៃការថែរក្សាសុវត្ថិភាព និងសន្តិសុខជូនទេសចរ ដែលជាកត្តាមិនអាចខ្វះបាន ដើម្បីការពារ និងទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ គ្រឹះស្ថានអង្គរ អាជ្ញាធរអប្សរា សាលាខេត្តសៀមរាប និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ